សម្រាប់វ៉ាក់សាំងក្រុមហ៊ុន
អាស្ត្រាហ្សេនីកា
(ខែសីហា ឆ្នាំ2021)

# សេចក្តីណែនាំអំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា

◎ ជាគោលការណ៍ សូមប្រើប្រាស់វ៉ាក់សាំងនេះសម្រាប់អ្នកដែលមានអាយុ40ឆ្នាំឡើង លើកលែងករណីចាំបាច់។
◎ ក្នុងករណីអ្នកមិនអាចចាក់វ៉ាក់សាំងកូវីដប្រភេទផ្សេងដោយសារមានប្រតិកម្មនឹងសារធាតុផ្សំដែលមានក្នុងវ៉ាក់សាំងនោះ ហើយអ្នកមានបំណងចង់ចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកានេះ អ្នកអាចទទួលការចាក់វ៉ាក់សាំងនេះបាន ទោះបីជាអ្នកមានអាយុក្រោម40ឆ្នាំក៏ដោយ (មិនក្រោម១៨ឆ្នាំ)។
◎ ថ្មីៗនេះជាករណីកម្រ នៅបរទេសត្រូវបានគេរាយការណ៍មកថាមានការកើតឡើងនូវអាការៈមិនប្រក្រតីផ្នែកស្រទាប់ជុំវិញសរសៃប្រសាទ (demyelinating disorders) ដូចជាបង្កអោយមានការកកឈាម ថយចុះនូវប្លាកែត ប្រេះឃើញបន្ទះឈាមឆ្នារៗក្នុងស្បែក និងជំងឺប្រព័ន្ធភាពស៊ាំនៃប្រព័ន្ធសរសៃប្រសាទវាយប្រហារសរសៃប្រសាទនៅខាងក្រៅខួរក្បាល និងខួរឆ្អឹងខ្នង(អាចបណ្តាលអោយពិការ)(Guillain-Barre syndrome) ជាដើម។ សូមស្វែងយល់អំពីផលប៉ះពាល់ និងអត្ថប្រយោជន៍របស់វ៉ាក់សាំងអោយបានច្បាស់លាស់មុននឹងសម្រេចចិត្តទទួលយកការចាក់វ៉ាក់សាំង។

## អំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា

វ៉ាក់សាំងនេះគឺជាផ្នែកមួយនៃកម្មវិធីចាក់វ៉ាក់សាំងរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងតាមមូលដ្ឋានសម្រាប់ការបង្ការមេរោគកូរ៉ូណា (SARS-CoV-2)។
វ៉ាក់សាំងនេះត្រូវបានឧបត្ថម្ភដោយថវិកាសាធារណៈ ហើយការចាក់វ៉ាក់សាំងនេះនឹងមិនគិតថ្លៃឡើយ។

## ប្រសិទ្ធភាពរបស់វ៉ាក់សាំង និងវិធីសាស្ត្រចាក់វ៉ាក់សាំង

វ៉ាក់សាំងដែលចាក់លើកនេះគឺជាវ៉ាក់សាំងរបស់ក្រុមហ៊ុនអាស្ត្រាហ្សេនីកា។ វ៉ាក់ស៊ាំងនេះ នឹងបង្ការការចេញរោគសញ្ញាណនៃជំងឺឆ្លងកូវីដ19។
គេបានរកឃើញថា ក្នុងចំណោមអ្នកដែលបានចាក់វ៉ាក់សាំងនេះរួច មានអត្រាចេញនូវរោគសញ្ញានៃជំងឺឆ្លងនេះទាបជាងអ្នកដែលមិនបានចាក់។ (តាមរយៈការពិសោធន៍បានបង្ហាញថា វាមានប្រសិទ្ធភាពបង្ការការចេញរោគសញ្ញាបានប្រមាណ70%។)

| | |
|---|---|
| ឈ្មោះវ៉ាក់សាំង | ថ្នាំចាក់សាច់ដុំ VAXZEVRIA ® |
| ប្រសិទ្ធផល និងប្រសិទ្ធភាព | ការបង្ការជំងឺឆ្លងដែលបង្កឡើងដោយវីរុស SARS-CoV-2 |
| ភាពញឹកញាប់ និងចន្លោះពេលវេលានៃការចាក់ វ៉ាក់សាំង | 2 ដង (ជាធម្មតា គម្លាត4-12សប្តាហ៍) *ការចាក់សាច់ដុំ |
| បុគ្គលដែលអាចចាក់ វ៉ាក់សាំងបាន | ជាគោលការណ៍ចាប់ពីអាយុ40ឆ្នាំឡើង |
| បរិមាណវ៉ាក់សាំង | 1 ដង 0.5 mL សរុប 2 ដង |

- យោងតាមការ យោងតាមការអនុម័តរបស់ក្រសួងក្រសួងសុខាភិបាល ក្រោយការចាក់លើកទី1 ត្រូវទទួលការចាក់លើកទី2 ដោយទុកគម្លាត 4-12 សប្តាហ៍។ យ៉ាងណាមិញ ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់បំផុត អ្នកគួរទុកគម្លាតចាប់ពី8សប្តាហ៍ឡើងទើបជាការប្រសើរ។ ម្យ៉ាងទៀត ករណីលើស 12សប្តាហ៍បន្ទាប់ពីចាក់លើកទី 1 សូមទទួលការចាក់លើកទី2 ឲ្យបានលឿនបំផុតតាមដែលអាច។
- ចំពោះអាយុជាគោលដៅចាក់វ៉ាក់ស៊ាំង ដោយយោងតាមការអនុម័ត វាមានសុវត្ថិភាព និងប្រសិទ្ធភាពសម្រាប់អ្នកដែលមានអាយុចាប់ពី 18ឆ្នាំឡើង។ ប៉ុន្តែដោយពិចារណាតាមស្ថានភាពនៃការណែនាំអោយប្រើប្រាស់វ៉ាក់ស៊ាំងរបស់បណ្តាលប្រទេសមួយចំនួន និងរបាយការណ៍ទាក់ទងអំពីហានិភ័យ និងគុណសម្បត្តិនៃវ៉ាក់ស៊ាំងតាមក្រុមអាយុ នាពេលបច្ចុប្បន្ន ជាគោលការណ៍ត្រូវបានកំណត់យកអ្នកដែលមានអាយុចាប់ពី 40ឆ្នាំឡើងតែប៉ុណ្ណោះ។
- ករណីលើកទី1 អ្នកបានចាក់វ៉ាក់សាំងនេះ សូមប្រាកដថាអ្នកទទួលបានការចាក់វ៉ាក់សាំងដូចគ្នានេះនៅលើកទី2 ដែរ។
- តាមរយៈការពិសោធន៍បានបញ្ជាក់ថា បន្ទាប់ពីប្រមាណ15ថ្ងៃក្រោយនៃការចាក់វ៉ាក់សាំងលើកទី2 ទើបវ៉ាក់ស៊ាំងចាប់ផ្តើមមានប្រសិទ្ធភាពក្នុងប្រព័ន្ធភាពស៊ាំ។ ម្យ៉ាងទៀត ការបានចាក់វ៉ាក់សាំងមិនមែនមានន័យថាអាចជួយការពារការឆ្លងបានទាំងស្រុងនោះទេ។ ការអនុវត្តវិធានការទប់ស្កាត់ការឆ្លងអោយបានត្រឹមត្រូវគឺជារឿងចាំបាច់ទោះបីជាបាន ឬមិនបានចាក់វ៉ាក់សាំងក៏ដោយ។

## បុគ្គលដែលមិនអាចចាក់វ៉ាក់សាំងបាន

វ៉ាក់សាំងនេះមិនអាចផ្តល់ជូនបុគ្គលដែលមានលក្ខណៈដូចខាងក្រោមឡើយ។
សូមផ្តល់ដំណឹងដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះយោបល់មុនពេលចាក់វ៉ាក់សាំង
ប្រសិនបើអ្នកគិតថាលក្ខខណ្ឌណាមួយត្រូវនឹងស្ថានភាពរបស់អ្នក។

- បុគ្គលដែលមានគ្រុនក្តៅ (*1)
- បុគ្គលដែលមានជំងឺស្រួចស្រាល់ធ្ងន់ធ្ងរ
- បុគ្គលដែលធ្លាប់មានប្រវត្តិមានប្រតិកម្មធ្ងន់ធ្ងរ (*2) ជាមួយនឹងសារធាតុផ្សំនៃវ៉ាក់សាំងនេះ។
- អ្នកដែលក្រោយចាក់វ៉ាក់សាំងSARS-CoV-2 ធ្លាប់កើតមានអាការកកឈាមនៃវ៉ែន ឬអាកទែដែលភ្ជាប់មកជាមួយនូវអាការថយចុះប្លាកែត
- អ្នកដែលមានប្រវត្តិជំងឺ capillary leak syndrome (បន្ទះឈាមឆ្នារៗក្នុងស្បែក)
- បុគ្គលដែលមានលក្ខណៈដទៃក្រៅពីលក្ខខណ្ឌខាងលើដែលមានលក្ខណៈមិនសមស្របក្នុងការទទួលបានវ៉ាក់សាំងនេះ។

(*1) គ្រុនក្តៅជាទូទៅមានសីតុណ្ហភាពចាប់ព 37.5 អង្សារសេ ឡើងទៅ។ ប៉ុន្តែ
លក្ខខណ្ឌនេះមិនសមស្របសម្រាប់ករណីដែលជំងឺនេះត្រូវបានវាយតម្លៃជាគ្រុនក្តៅដោយពិចារណាលើសីតុណ្ហភាពរាងកាយធម្មតាឡើយ ទោះបីជារាងកាយមានសីតុណ្ហភាពទាបជាង 37.5 អង្សារក៏ដោយ ។
(*2) ជំងឺប្រតិកម្មធ្ងន់ធ្ងរទាន់ហន់ និងរោគសញ្ញាមួយចំនួនដែលបង្ហាញពីជំងឺប្រតិកម្មថ្នាំនេះ រួមមានដូចជា របកស្បែក និងរោគសញ្ញាមានភ្នាសរអិល ពិបាកដកដង្ហើម ដង្ហើមខ្លី បេះដូងលោតញាប់ និងសម្ពាធឈាមខ្សោយ ជាដើម។

## បុគ្គលដែលត្រូវប្រុងប្រយ័ត្នក្នុងការចាក់វ៉ាក់សាំង

បុគ្គលដែលមានលក្ខណៈដូចខាងក្រោមគួរតែប្រុងប្រយ័ត្នក្នុងការចាក់វ៉ាក់សាំងនេះ។ ប្រសិនបើអ្នកគិតថាខ្លួនមានលក្ខណៈ
ដូចខាងក្រោមនេះ សូមផ្តល់ដំណឹងដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះមុនពេលចាក់វ៉ាក់សាំង។

- បុគ្គលដែលកំពុងព្យាបាលការកកឈាម បុគ្គលដែលមានប្លាកែតថយចុះ ឬជំងឺកកឈាម។
- បុគ្គលដែលធ្លាប់ពិនិត្យឃើញថាខ្វះភាពស៊ាំ ឬបុគ្គលដែលមានសាច់ញាតិជិតស្និទ្ធខ្វះភាពស៊ាំពីកំណើត។
- បុគ្គលដែលមានជំងឺជាប់ខ្លួនស្រាប់ដូចជា ជំងឺបេះដូង តម្រងនោម ថ្លើម ជំងឺឈាម ឬ ជំងឺពាក់ព័ន្ធនឹងការលូតលាស់ ជាដើម។
- បុគ្គលដែលធ្លាប់ចាក់វ៉ាក់សាំងពីមុនមក ហើយកើតមានរោគសញ្ញាអាឡាក់ហ្ស៊ី ដូចជា គ្រុនក្តៅ ឬរមាស់ស្បែកនៅក្នុងអំឡុងពេល 2 ថ្ងៃបន្ទាប់ពីការចាក់វ៉ាក់សាំង។
- បុគ្គលដែលធ្លាប់មានជំងឺប្រកាច់កាលពីមុន
- បុគ្គលដែលអាចនឹងអាឡាក់ហ្ស៊ីជាមួយនឹងសារធាតុផ្សំនៃវ៉ាក់សាំងនេះ។

**(បន្តទៅខាងក្រោយ)**

ប្រសិនបើអ្នកមានផ្ទៃពោះ ឬអាចមានផ្ទៃពោះ ឬកំពុងបំបៅកូនដោយទឹកដោះ សូមផ្តល់ដំណឹងជូនដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះយោបល់មុនពេលចាក់វ៉ាក់សាំង។
វ៉ាក់សាំងនេះមានផ្ទុកសារធាតុបន្ថែមដែលមិនធ្លាប់មានប្រើនៅក្នុងវ៉ាក់សាំងពីមុនៗមកឡើយ។ ប្រសិនបើអ្នកធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរ ឬអាឡាក់ហ្ស៊ី ជាមួយនឹងថ្នាំពីមុនមក សូមផ្តល់ដំណឹងជូនដល់វេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងអំឡុងពេលពិគ្រោះយោបល់មុនពេលចាក់វ៉ាក់សាំង។

**សកម្មភាពដែលត្រូវធ្វើបន្ទាប់ពីទទួលបានវ៉ាក់សាំង**

- បន្ទាប់ពីចាក់វ៉ាក់សាំងនេះរួច សូមរង់ចាំនៅទីតាំងដែលអ្នកចាក់ថ្នាំនោះឱ្យបានយ៉ាងហោច 15 នាទី (យ៉ាងហោច 30 នាទីសម្រាប់បុគ្គលដែលធ្លាប់មានរោគសញ្ញាអាឡាក់ហ្ស៊ីធ្ងន់ធ្ងរ ដូចជាជំងឺប្រតិកម្មថ្នាំ ឬបុគ្គលដែលមានអារម្មណ៍មិនស្រួលខ្លួន ឬសន្លប់ ជាដើម។) ប្រសិនបើអ្នក មានអារម្មណ៍មិនស្រួលខ្លួន សូមទាក់ទងទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកភ្លាមៗ។ (ធ្វើបែបនេះអាចជួយឱ្យអ្នកអាចឆ្លើយតបទៅនឹងផលប៉ះពាល់ដែលអាចកើតមានឡើងភ្លាមៗនោះ)
- កន្លែងដែលចាក់ថ្នាំគួរតែរក្សាឱ្យស្អាត។ ទោះបីជាការអ្នកអាចងូតទឹកនៅថ្ងៃដែលចាក់ថ្នាំនោះបានក៏ដោយ ក៏អ្នកមិនត្រូវដុសកន្លែងដែលចាក់ថ្នាំនោះដែរ។
- អ្នកអាចធ្វើសកម្មភាពរស់នៅបានជាធម្មតា ប៉ុន្តែសូមជៀសវាងការហាត់ប្រាណខ្លាំងៗ និងពិសារគ្រឿងស្រវឹងច្រើនជ្រុលជាដើម នៅថ្ងៃចាក់ថ្នាំរួច។

**ផលប៉ះពាល់**

- ផលប៉ះពាល់ ទូទៅមានដូចជា ការឈឺចាប់ត្រង់កន្លែងដែលបានចាក់ ឈឺក្បាល ឈឺសន្លាក់ឬសាច់ដុំ ល្ហិតល្ហៃ អស់កម្លាំង ស្រៀវស្រាញ ក្តៅខ្លួនជាដើម។ នៅក្នុងការពិសោធន៍បានរកឃើញថា រោគសញ្ញាណទាំងនេះមានទំនោរលេចឡើងញឹកញាប់បន្ទាប់ពីការចាក់លើកទី១ ច្រើនជាងលើកទី២។ ម្យ៉ាងទៀត មានផលប៉ះពាល់ធ្ងន់ធ្ងរដែលកម្រនឹងកើតឡើងមានដូចជា សម្ពាធឈាមចុះលឿនខ្លាំង ឬប្រតិកម្មអាឡែកស៊ីធ្ងន់ធ្ងរ។ ដោយសារវ៉ាក់សាំងនេះគឺជាវ៉ាក់សាំងប្រភេទថ្មី ទើបថ្នាំនេះអាចនឹងបង្កឱ្យមានរោគសញ្ញាដែលមិនទាន់អាចបញ្ជាក់ច្បាស់ រហូតមកដល់ពេលនេះ។ ប្រសិនបើអ្នកកត់សម្គាល់ឃើញមានរោគសញ្ញាណាមួយបន្ទាប់ពីការចាក់វ៉ាក់សាំងរួច សូមពិគ្រោះជាមួយនឹងវេជ្ជបណ្ឌិតដែលចាក់វ៉ាក់សាំងនោះ ឬវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នក។
- ថ្វីត្បិតជាករណីកម្រ នៅបរទេសត្រូវបានគេរាយការណ៍មកថាមានការកើតឡើងនូវអាការៈមិនប្រក្រតីផ្នែកស្រទាប់ជុំវិញសរសៃប្រសាទ (demyelinating disorders) ដូចជាបង្កអោយមានការកកឈាម ថយចុះនូវប្លាកែត(*1) ប្រទះឃើញបន្ទះឈាមឆ្នារៗក្នុងស្បែក(*2) និងជំងឺប្រព័ន្ធភាពស៊ាំនៃប្រព័ន្ធសរសៃប្រសាទវាយប្រហារសរសៃប្រសាទនៅខាងក្រៅខួរក្បាល និងខួរឆ្អឹងខ្នង(*3) បន្ទាប់ពីចាក់វ៉ាក់សាំងរួច។ ប្រសិនបើបើអ្នកមានរោគសញ្ញាណាមួយដូចខាងក្រោមនេះ សូមទៅពិគ្រោះនៅគ្រឹះស្ថានព្យាបាលជាបន្ទាន់។
- (*1) អាការដូចជា ឈឺក្បាលខ្លាំងជាប់ ស្រវាំងភ្នែក ដង្ហើមខ្លី វង្វេងវង្វាន់ ញ័រញាក់កន្ត្រាក់ ឈឺទ្រូង ហើមឬឈឺជើង ឈឺពោះជាប់ ខ្ទាំឈាម(ជាំ)នៅក្រៅពីកន្លែងចាក់វ៉ាក់សាំង ។ល។ គួរបញ្ជាក់ថា ភាគច្រើននៃរោគសញ្ញានេះ ជាទូទៅកើតមានក្នុងរង្វង់28ថ្ងៃ បន្ទាប់ពីចាក់វ៉ាក់សាំងរួច និងកើតមានឡើងនៅក្រោយពេលចាក់លើកទី១ ច្រើនជាងលើកទី២។
  - (*2) រោគសញ្ញាដូចជា ហើមដៃជើង សម្ពាធឈាមទាប ។ល។
  - (*3) ចុះខ្សោយក្នុងការធ្វើចលនាដូចជា ពិបាកក្នុងការធ្វើបញ្ជូនកម្លាំងមកដៃជើង ចុះខ្សោយផ្នែកវិញ្ញាណដូចជាស្ពឹក បញ្ហាក្នុងការបន្ទោរបង់ និង ចុះខ្សោយសុខភាពភ្នែកដូចជាស្រវាំងភ្នែក។

**អំពីប្រព័ន្ធជំនួយសម្រាប់ការរងផលប៉ះពាល់ដល់សុខភាពដោយសារការចាក់វ៉ាក់សាំង**

ការចាក់វ៉ាក់សាំងអាចបង្កឱ្យមានបញ្ហាសុខភាព (ជំងឺ ឬពិការភាព)។ ទោះបីជាករណីទាំងនោះកម្រកើតឡើងយ៉ាងណាក៏ដោយ ក៏មិនអាចផាត់ចោលហានិភ័យបានដែរ ហើយប្រព័ន្ធជំនួយត្រូវបានបង្កើតឡើងគឺសម្រាប់ហេតុផលនេះហើយ។
នៅក្នុងករណីដែលមានការប៉ះពាល់ដល់សុខភាពដោយសារតែការចាក់វ៉ាក់សាំង ជំនួយ (ចំណាយលើការព្យាបាល ប្រាក់អត្ថប្រយោជន៍ជនពិការ ជាដើម) ក៏មានផ្តល់ជូនផងដែរនៅក្រោមច្បាប់នៃការចាក់វ៉ាក់សាំង។
សូមពិគ្រោះជាមួយនឹងសាលាក្រុងរបស់អ្នកអំពីនីតិវិធីចាំបាច់សម្រាប់ការបំពេញបែបបទ។

---

**អំពីការឆ្លងមេរោគកូរ៉ូណា**

នៅពេលដែលឆ្លងវីរុស SARS-CoV-2 អ្នកអាចនឹងមានរោគសញ្ញាស្រដៀងនឹងជំងឺផ្តាសាយ ដូចជា គ្រុនក្តៅ និងក្អក ជាដើម។
ទោះបីជាមានមនុស្សជាច្រើនបានធូរស្រាលពីជំងឺនេះដោយមានរោគសញ្ញាតិចតួចក្តី នៅក្នុងករណីធ្ងន់ធ្ងរមួយចំនួន រោគសញ្ញារលាកសួត ដូចជាពិបាកដកដង្ហើមខ្លាំងទៅៗ ហើយថែមទាំងអាចគ្រោះថ្នាក់ដល់អាយុជីវិតថែមទៀត។
5

**លក្ខណៈសម្គាល់របស់វ៉ាក់សាំងមេរោគកូរ៉ូណា (**វ៉ាក់សាំងផលិតដោយក្រុមហ៊ុន**) ដែលនឹងយកមកប្រើប្រាស់នៅលើកនេះ**

ថ្នាំនេះគឺជាវ៉ាក់សាំងវ៉ាយរលវិចទ័រ(viral vector) ហើយជាថ្នាំដែលបញ្ចូលហ្សែនដែលបំប្លែងជាកូដនូវលំដាប់តម្រៀបនៃអាស៊ីតអាមីណូ របស់ប្រូតេអ៊ីនបន្លា(spike protein)(ប្រូតេអ៊ីនចាំបាច់របស់វីរុសដើម្បីជ្រៀតចូលក្នុងកោសិកាមនុស្ស) នៃវីរុសSARS-CoV-2 ទៅក្នុង ស៊ីមៀនអាដេណូវីរុស(simian adenovirus) (ធ្វើឲ្យអាដេណូវីរុសដែលជាវីរុសផ្តាសាយ មិនអាចបង្កើនបរិមាណបាន) ។
នៅពេលហ្សែននេះត្រូវបានបញ្ចូលទៅក្នុងកោសិការបស់មនុស្សតាមរយៈការចាក់វ៉ាក់សាំងនេះ ប្រូតេអ៊ីនបន្លា(spike protein)របស់វីរុសនឹងត្រូវបានបង្កើតនៅក្នុងកោសិកាដោយផ្អែកតាមហ្សែននេះ ហើយតាមរយៈការដឹកនាំឲ្យបង្កើតអង់ទីករប្រឆាំងទៅនឹងប្រូតេអ៊ីនបន្លា(spike protein)ព្រមទាំងឆ្លើយតបដោយប្រព័ន្ធភាពស៊ាំកោសិកា គេជឿថានឹងអាចបង្ការជំងឺឆ្លងបង្កដោយវីរុសSARS-CoV-2បាន។

ថ្នាំនេះមានផ្សំឡើងពីគ្រឿងដូចខាងក្រោម៖

| | | | |
|---|---|---|---|
| សារធាតុផ្សំសកម្ម | ✧ វ៉ាក់សាំងវីរុសកូរ៉ូណា(SARS-CoV-2) (វ៉ាយរ៉លវិចទ័រ(viral vector)នៃស៊ីមៀនអាដេណូវីរុស(simian adenovirus)ដែលត្រូវបានផ្លាស់ប្តូរហ្សែន)<br>(សំគាល់៖ ស៊ីមៀនអាដេណូវីរុសដែលត្រូវបានបញ្ចូលហ្សែនដែលបំប្លែងជាកូដនូវលំដាប់តម្រៀបនៃអាស៊ីតអាមីណូរបស់ប្រូតេអ៊ីនបន្លា(spike protein)របស់វីរុសSARS-CoV-2) | | |
| ធាតុផ្សំបន្ថែម | ✧ L-histidine<br>✧ ម៉ាញ៉េស្យូមក្លរួ<br>✧ អេតាណុលគ្មានជាតិទឹក | ✧L-histidine hydrochloride monohydrate<br>✧disodium edetate dihydrate<br>✧polysorbate 80 | ✧សូដ្យូមក្លរួ<br>✧ស្ករសុទ្ធ |

| | |
|---|---|
| សម្រាប់ព័ត៌មានបន្ថែមអំពីប្រសិទ្ធភាព និងសុវត្ថិភាពរបស់វ៉ាក់សាំងសម្រាប់មេរោគកូរ៉ូណា សូមចូលទៅកាន់ទំព័រវ៉ាក់សាំងសម្រាប់មេរោគកូរ៉ូណានៅលើវែបសាយរបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព។ | ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព វ៉ាក់សាំងមេរោគកូរ៉ូណានា ស្វែងរក |
| ប្រសិនបើអ្នកមិនអាចបើកវែបសាយនោះបានទេ សូមទាក់ទងទៅកាន់សាលាក្រុងក្នុងមូលដ្ឋានរបស់អ្នក។ | |